ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស
អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខ ១១៩/១៩ [illegible]

## សូមគោរពជូន

## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ជាទីគោរពដ៏ខ្ពង់ខ្ពស់

**កម្មវត្ថុ៖** របាយការណ៍ស្តីពី «ការរៀបចំមុខងារ និងកំណត់ចំនួនក្របខ័ណ្ឌក្នុងរចនាសម្ព័ន្ធ ចំណុះអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)»។

**យោង៖** - ប្រកាសលេខ ១៤២៩៦ ប្រ.ក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៦ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតគណៈកម្មការរៀបចំមុខងារ និងកំណត់ចំនួនក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងមន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ

-ប្រកាសលេខ ៦៦០៤ ប្រ.ក ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការកណត់ចំនួនមុខតំណែងអគ្គស្នងការរង អគ្គនាយករង អនុប្រធាននាយកដ្ឋានកណ្តាល អនុប្រធាននាយកដ្ឋាន នាយរងការិយាល័យ និងថ្នាក់ប្រហាក់ប្រហែលក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ និងក្របខ័ណ្ឌពន្ធនាគារ ក្រសួងមហាផ្ទៃ

- ស្មារតីកិច្ចប្រជុំថ្ងៃអង្គារ ០៩ កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី ២៦ ខែធ្នូឆ្នាំ២០១៧ នៅទីស្តីការក្រសួងមហាផ្ទៃ ស្តីពីការរៀបចំមុខងារ និងកំណត់ចំនួនក្របខ័ណ្ឌមន្ត្រីរាជការ របស់ក្រសួងមហាផ្ទៃ

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំមានកិត្តិយស សូមគោរពជម្រាបជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា យោងអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៥ "ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ" និងអនុក្រឹត្យលេខ ២៧៣អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ២០១៤ "ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស"អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានរៀបចំការវិភាគមុខងារ និងកំណត់ចំនួនក្របខ័ណ្ឌក្នុងរចនាសម្ព័ន្ធ ចំណុះអគ្គលេខាធិការដ្ឋានរួចហើយ (ដោយមិនរាប់បញ្ចូលរចនាសម្ព័ន្ធដែលពាក់ព័ន្ធនឹងអន្តរក្រសួង និងរាជធានី-ខេត្តទេ)។ បន្ទាប់ពីធ្វើការបូកសរុបចំនួនក្របខ័ណ្ឌដែលមានបច្ចុប្បន្ន និងក្របខ័ណ្ឌដែលជាតម្រូវការមានដូចខាងក្រោម៖

**រចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជចែកចេញជា ៖**

- អគ្គលេខាធិការ ០១រូប
- អគ្គលេខាធិការរង ០៧រូប (បច្ចុប្បន្នមាន០៦រូប)
  និងថ្នាក់ដឹកនាំ ដែលមាន មានឋានៈ និងបុព្វសិទ្ធិស្មើ៖
- ប្រធាននាយកដ្ឋាន ជាប្រធានលេខាធិការដ្ឋាន និងប្រធាន ក្រុមជំនួយកិច្ចការ (បច្ចេកទេស) ទាំង ០៦ក្រុម
- ជាអនុប្រធាននាយកដ្ឋានជាអនុប្រធានលេខាធិការដ្ឋាន និងជាអនុប្រធានក្រុមជំនួយកិច្ចការ (បច្ចេកទេស) ទាំង០៦ក្រុម ។

តារាងវិភាគមុខងារ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖

| ឈ្មោះអង្គភាព | តួនាទី | ជាក់ស្តែង | តម្រូវការ | លើស | ខ្វះ | សេចក្តីបញ្ជាក់ |
|---|---|---|---|---|---|---|
| ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន | | | | | | |
| | អគ្គលេខាធិការ | ០១ | ០១ | | | |
| | អគ្គ.រង | ០៦ | ០៧ | | ០១ | |
| | ទីប្រឹក្សា គ.ជ.ប.ជ | ០១ | ០១ | | | |
| | សរុប | ០៨ | ០៩ | ខ្វះអគ្គលេខាធិការរង០១ | | |
| លេខាធិការដ្ឋានរដ្ឋបាលសរុប | | | | | | |
| | ប្រធាន | ០១ | ០១ | | | អគ្គលេខាធិការរង០១រូប ទទួលបន្ទុក (ឯ.ឧត្តមសេនីយ៍ឯក ម៉ែម ចំនួណារុំ) |
| | អនុប្រធាន | ០៨ | ០៨ | | | |
| | នាយការិ. | ០៥ | ០៥ | | | |
| | នាយរងការិ. | ១៤ | ២០ | | ០៦ | |
| | នាយផ្នែក | ០២ | ០២ | | | |
| | មន្ត្រី | ០៣ | ២៥ | | ២២ | |
| | សរុប | ៣៣ | ៦១ | ០០ | ខ្វះ ២៨ | |
| | ១.ការិយាល័យ រដ្ឋបាល | | | | | |
| | នាយការិ. | ០១ | | | | |
| | នាយរងការិ. | ០២ | ០៤ | | ០២ | |
| | នាយផ្នែក | ០១ | | | | |
| | នាយរងផ្នែក | ០០ | | | | |
| | មន្ត្រី | ០១ | ០៥ | | ០៤ | |
| | ២.ការិយាល័យ ផែនការ ហិរញ្ញកិច្ច និងទស្សនការ | | | | | |
| | នាយការិ. | ០១ | | | | |
| | នាយរងការិ. | ០៣ | ០៤ | | ០១ | |
| | នាយផ្នែក | ០១ | | | | |
| | នាយរងផ្នែក | ០០ | | | | |
| | មន្ត្រី | ០១ | ០៥ | | ០៤ | |
| | ៣.ការិយាល័យ ស្រាវជ្រាវព័ត៌មាន និងគ្រួតពិនិត្យ | | | | | |
| | នាយការិ. | ០១ | | | | |
| | នាយរងការិ. | ០៣ | ០៤ | | ០១ | |
| | នាយផ្នែក | ០០ | | | | |
| | នាយរងផ្នែក | ០០ | | | | |
| | មន្ត្រី | ០១ | ០៥ | | ០៤ | |
| | ៤.ការិយាល័យ ផ្សព្វផ្សាយ អប់រំ | | | | | |
| | នាយការិ. | ០១ | | | | |
| | នាយរងការិ. | ០៤ | ០៤ | | | |
| | នាយផ្នែក | ០០ | | | | |
| | នាយរងផ្នែក | ០០ | | | | |
| | មន្ត្រី | ០០ | ០៥ | | ០៥ | |

| ឈ្មោះអង្គភាព | តួនាទី | ជាក់ស្តែង | តម្រូវការ | លើស | ខ្វះ | សេចក្តីបញ្ជាក់ |
|---|---|---|---|---|---|---|
| | **៥.ការិយាល័យ សរុប និងផែនការ** | | | | | អគ្គលេខាធិការរង០១រូប ទទួលបន្ទុក (ឯ.ឧត្តមសេនីយ៍ឯក យ៉ែម ច័ន្ទណារុំ) |
| | នាយការិ. | ០១ | | | | |
| | នាយរងការិ. | ០២ | ០៤ | | ០២ | |
| | នាយផ្នែក | ០០ | | | | |
| | នាយរងផ្នែក | ០០ | | | | |
| | មន្ត្រី | ០០ | ០៥ | | ០៥ | |
| **ក្រុមមន្ត្រីជំនួយកិច្ចការទាំង៦**(មានឋានៈ និងបុព្វសិទ្ធិស្មើប្រធាន ឬអនុប្រធាននាយកដ្ឋាន)៖ | | | | | | |
| | ប្រធាន | ០៥ | ០៦ | | ០១ | |
| | អនុប្រធាន | ២០ | ៣០ | | ១០ | |
| | មន្ត្រី | ១២ | ៣០ | | ១៨ | |
| | សរុប | ៣៧ | ៦៦ | ០០ | ២៩ | |
| | **១.ក្រុមជំនួយកិច្ចការ បង្ការទប់ស្កាត់** | | | | | អគ្គលេខាធិការរង០១រូប ទទួលបន្ទុក (ឯ.ឧត្តមសេនីយ៍ឯក ស៊ុន រ៉ូ) |
| | ប្រធាន | ០១ | ០១ | | | |
| | អនុប្រធាន | ០៣ | ០៥ | | ០២ | |
| | មន្ត្រី | ០៣ | ០៥ | | ០២ | |
| | **២.ក្រុមជំនួយកិច្ចការ ការពារជនរងគ្រោះ** | | | | | អគ្គលេខាធិការរង០១រូប ទទួលបន្ទុក (ឯ.ឧត្តមសេនីយ៍ទោ អ៊ូ ម៉ានីរ៉ា) |
| | ប្រធាន | ០១ | ០១ | | | |
| | អនុប្រធាន | ០៣ | ០៥ | | ០២ | |
| | មន្ត្រី | ០១ | ០៥ | | ០៤ | |
| | **៣. ក្រុមជំនួយកិច្ចការ អនុវត្តច្បាប់** | | | | | |
| | ប្រធាន | ០១ | ០១ | | | |
| | អនុប្រធាន | ០៣ | ០៥ | | ០២ | |
| | មន្ត្រី | ០២ | ០៥ | | ០៣ | |
| | **៤.ក្រុមជំនួយកិច្ចការ យុត្តិធម៌** | | | | | អគ្គលេខាធិការរង០១រូប ទទួលបន្ទុក (ឯ.ឧត្តមសេនីយ៍ឯក ឃឹម វិរៈ) |
| | ប្រធាន | ០០ | ០១ | | ០១ | |
| | អនុប្រធាន | ០៣ | ០៥ | | ០២ | |
| | មន្ត្រី | ០៣ | ០៥ | | ០២ | |
| | **៥.ក្រុមជំនួយកិច្ចការ កិច្ចសហប្រតិបត្តិការអន្តរជាតិ** | | | | | អគ្គលេខាធិការរង០១រូប ទទួលបន្ទុក (លោកជំទាវ ឧត្តមសេនីយ៍ទោ វ៉ន ស៊ីរីលក្ខិណា) |
| | ប្រធាន | ០១ | ០១ | | | |
| | អនុប្រធាន | ០៣ | ០៥ | | ០២ | |
| | មន្ត្រី | ០២ | ០៥ | | ០៣ | |
| | **៦.ក្រុមជំនួយកិច្ចការ ទេសន្តរប្រវេសន៍** | | | | | អគ្គលេខាធិការរង០១រូប ទទួលបន្ទុក (ឯ.ឧត្តមសេនីយ៍ឯក ខៀវ ចាន់រ៉ា) |
| | ប្រធាន | ០១ | ០១ | | | |
| | អនុប្រធាន | ០៥ | ០៥ | | | |
| | មន្ត្រី | ០១ | ០៥ | | ០៤ | |

| តួនាទី | ជាក់ស្តែង | តម្រូវការ | លើស | ខ្វះ | សេចក្តីបញ្ជាក់ |
|---|---|---|---|---|---|
| **សរុបរួម** | | | | | |
| ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន | ០៧ | ០៨ | ០០ | ០១ | |
| ទីប្រឹក្សា គ.ជ.ប.ជ | ០១ | ០១ | ០០ | ០០ | |
| លេខាធិការដ្ឋានរដ្ឋបាលសរុប | ៣៣ | ៦១ | ០០ | ២៨ | |
| ក្រុមជំនួយកិច្ចការទាំង៦ | ៣៧ | ៦៦ | ០០ | ២៩ | |
| សរុបរួម | ៧៨ | ១៣៦ | ០០ | ៥៨ | |

**<u>សរុបមកក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖</u>**

**បច្ចុប្បន្នភាព៖**

ក្របខ័ណ្ឌសរុប៖ ៧៨នាក់ ស្រី១១នាក់ ជាក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ៖

- អគ្គលេខាធិការ ០១រូប
- អគ្គលេខាធិការរង ០៦រូប
- មន្ត្រីក្នុងលេខាធិការដ្ឋាន(០៥ការិយាល័យ)៖ ៣៥រូប
- មន្ត្រីជំនាញក្នុងក្រុមជំនួយកិច្ចការ(០៦ក្រុម) ៖ ៣៦រូប។

តម្រូវការក្របខ័ណ្ឌសរុប៖ ១៣៦រូប

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន៖ ០៨រូប (ខ្វះអគ្គលេខាធិការរង ០១រូប)
- ទីប្រឹក្សា គ.ជ.ប.ជ ០១រូប
- ថ្នាក់ដឹកនាំលេខាធិការដ្ឋាន៖ ប្រធានលេខាធិការដ្ឋាន ០១រូប អនុប្រធានលេខាធិការដ្ឋាន ០៨រូប
- ថ្នាក់ដឹកនាំការិយាល័យ(០៥ការិយាល័យ)៖ នាយការិយាល័យ ០៥រូប នាយរងការិយាល័យ ២០រូប(ខ្វះនាយរងការិយាល័យ ០៦រូប) និងនាយផ្នែក ០២រូប
- ថ្នាក់ដឹកនាំក្រុមជំនួយកិច្ចការ(បច្ចេកទេស) ក្នុងនោះ៖ ប្រធានក្រុម មានឋានៈស្មើប្រធាននាយកដ្ឋាន ០៦រូប(ខ្វះ០១រូប) និងអនុប្រធានក្រុម មានឋានៈ និងបុព្វសិទ្ធិស្មើអនុប្រធាននាយកដ្ឋាន ៣០រូប(ខ្វះ ១០រូប)
- មន្ត្រីក្នុងលេខាធិការដ្ឋាន(០៥ការិយាល័យ)៖ ២៥រូប (ខ្វះមន្ត្រីក្របខណ្ឌ ២២រូប)
- មន្ត្រីក្នុងក្រុមជំនួយកិច្ចការ(០៦ក្រុម)៖ ៣០រូប(ខ្វះមន្ត្រីក្របខណ្ឌ ១៨រូប)

(ខ្វះមន្ត្រីក្របខ័ណ្ឌសរុប៖ ៤០រូប) ។

**<u>សំណូមពរ៖</u>**

- ស្នើសុំតែងតាំង៖
  - អគ្គលេខាធិការរង ០១រូប
  - ប្រធានក្រុមមន្ត្រីជំនួយកិច្ចការយុត្តិធម៌ ០១រូប ។
  - អនុប្រធានក្រុមមន្ត្រីជំនួយកិច្ចការ(បច្ចេកទេស)១០រូប ក្នុងនោះ៖
    - ក្រុមមន្ត្រីជំនួយកិច្ចការបង្ការ ទប់ស្កាត់ ០២រូប
    - ក្រុមមន្ត្រីជំនួយកិច្ចការការពារជនរងគ្រោះ ០២រូប
    - ក្រុមមន្ត្រីជំនួយកិច្ចការអនុវត្តច្បាប់ ០២រូប
    - ក្រុមមន្ត្រីជំនួយកិច្ចការយុត្តិធម៌ ០២រូប
    - ក្រុមមន្ត្រីជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ០២រូប ។

- នាយរងការិយាល័យ ០៦រូប ក្នុងនោះ៖
  - ការិយាល័យរដ្ឋបាល ០២រូប
  - ការិយាល័យសរុប ផែនការ ០២រូប
  - ការិយាល័យស្រាវជ្រាវព័ត៌មាន ត្រួតពិនិត្យ ០១រូប
  - ការិយាល័យផែនការហិរញ្ញវត្ថុ និងកស្តុការ ០១រូប ។

- ស្នើសុំជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី ចំនួន៤០រូប ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ថ្ងៃ [illegible] ខែ[illegible] ឆ្នាំកុរ ឯកស័ក ពស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០១៩

**ជ.គណៈកម្មាធិការជាតិ**

**អនុប្រធានអចិន្ត្រៃយ៍** K.

ជូ_ប៊ុនអេង